ក្រសួងការពារជាតិ

# សេចក្តីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់ ឯកឧត្តម **ឧត្តមសេនីយ៍ឯក ខាំលៀង ឧថាក់កែសន** រដ្ឋមន្ត្រីក្រសួងការពារប្រទេស នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ **ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ សីហា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នឹងដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ ចូលរួមក្នុងពិធីអបអរសាទរទិវាថ្ងៃបង្កើតសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ **គម្រប់ខួប ៥០ឆ្នាំ "២ ធ្នូ ១៩៧៥- ២ ធ្នូ ២០២៥ "** ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥ នៅរដ្ឋធានីវៀងចន្ទន៍ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

ពិធីអបអរសាទរទិវាថ្ងៃបង្កើតសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ **គម្រប់ខួប ៥០ឆ្នាំ "២ ធ្នូ ១៩៧៥- ២ ធ្នូ ២០២៥ " គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏សំខាន់មួយក្នុងដំណើរជាតិ** នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។ ក្នុងឱកាសចូលរួមក្នុងពិធីអបអរសាទរទិវាថ្ងៃបង្កើតសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវគម្រប់ខួប ៥០ឆ្នាំ ឯកឧត្តម នាយឧត្តមសេនីយ៍ **ទៀ សីហា** នឹងចូលជួបសម្តែងការគួរសម ឯកឧត្តម ឧត្តមសេនីយ៍ឯក **ខាំលៀង ឧថាក់កែសន** រដ្ឋមន្ត្រីក្រសួងការពារប្រទេសឡាវ ។

ដំណើរទស្សនកិច្ចរបស់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នឹងបញ្ជាក់ឡើងវិញនូវការរឹតចំណងសាមគ្គីភាព មិត្តភាព រវាងកងទ័ព និង ប្រជាជន នៃប្រទេសទាំងពីរ កម្ពុជា ឡាវ និង ជំរុញកិច្ចសហប្រតិបត្តិការ ការពារជាតិរវាងប្រទេសទាំងពីរ ឱ្យកាន់តែរឹងមាំបន្ថែមទៀត ដើម្បីរួមគ្នាថែរក្សានូវសុខសន្តិភាព ស្ថិរភាព និង ការអភិវឌ្ឍប្រកបដោយចីរភាពទៅថ្ងៃអនាគត ។

ថ្ងៃអាទិត្យ ១០កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៥